# សុន្ទរកថា

## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបិទ «វេទិកាជាតិអេកូទេសចរណ៍លើកទី ៣»

*សណ្ឋាគារហ្គាឌិនស៊ីធី, ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០២២*

- *ឯកឧត្តមបណ្ឌិត **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍;*
- *ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន;*
- *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

ជាបឋម, ខ្ញុំសូមអរគុណ **ឯកឧត្តមបណ្ឌិត ថោង ខុន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និង ជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង និង អភិវឌ្ឍ សហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ (គ.ជ.អ.អ.)** ដែលបានផ្តល់នូវរបាយការណ៍បូកសរុបយ៉ាងក្បោះក្បាយប្រកបដោយអត្ថន័យ ។

ថ្ងៃនេះ, ខ្ញុំពិតជាមានកិត្តិយស និង សេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ **ព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតីក្នុងពិធីបិទ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** ។ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និង វាយតម្លៃខ្ពស់ ចំពោះ **គ.ជ.អ.អ.**, ក្រសួងទេសចរណ៍, ក្រសួងបរិស្ថាន, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ព្រមទាំងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលបានសហការរៀបចំ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** នេះ ប្រកបដោយជោគជ័យ ។

ការរៀបចំ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** គឺជាសក្ខីភាពនៃស្មារតីសហការខ្ពស់ពីគ្រប់មជ្ឈដ្ឋាន ដើម្បីជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ ឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត តាមរយៈការចែករំលែកនូវមតិយោបល់, ទស្សនាទាន និង បទពិសោធន៍សំខាន់ៗ សំដៅស្វែងរកដំណោះស្រាយ និង កំណត់ទិសដៅរួម សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ តាមគន្លងប្រក្រតីភាពថ្មី ។ ក្នុងស្មារតីនេះ, ខ្ញុំជឿជាក់យ៉ាងមុតមាំថា យើងទាំងអស់គ្នានឹងសម្រេចបាននូវសមិទ្ធផលសំខាន់ៗបន្ថែមទៀត សម្រាប់វិស័យទេសចរណ៍, ជាពិសេស ក្នុងការអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ សំដៅប្រែក្លាយប្រទេសកម្ពុជាឱ្យទៅជាគោលដៅទេសចរណ៍លំដាប់ពិភពលោក ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

បច្ចុប្បន្ននេះ, ទោះបីជាវិបត្តិនៃជំងឺកូវីដ-១៩ បានថមថយក្តី, ក៏បញ្ហាអស្ថិរភាពសេដ្ឋកិច្ច និង ភូមិសាស្ត្រនយោបាយសកល បន្តបន្ទច់បង្អាក់ដល់ការស្តារ និង ជំរុញវិស័យទេសចរណ៍ឡើងវិញ ដោយសារកំណើនភ្ញៀវទេសចរអន្តរជាតិនៅមានកម្រិតទាបនៅឡើយ ។ ក្នុងបរិការណ៍មិនប្រាកដប្រជានេះ, ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលនៅតែចាត់ទុកវិស័យទេសចរណ៍ជាវិស័យអាទិភាពមួយ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលវែងទៅមុខ និង បន្តប្តេជ្ញាខិតខំប្រឹងប្រែងផ្តល់ការគាំទ្រនានា ដើម្បីស្តារវិស័យនេះឡើងវិញឱ្យបានឆាប់រហ័ស ។ ជាក់ស្តែង, ដើម្បីគាំទ្រដល់ការស្តារឡើងវិញនៃវិស័យទេសចរណ៍, រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការអន្តរាគមន៍ជាបន្តបន្ទាប់ មានជាអាទិ៍ៈ វិធានការសារពើពន្ធ, ការកសាងហេដ្ឋាចនាសម្ព័ន្ធតភ្ជាប់ក្នុងខេត្តដែលមានសក្តានុពលទេសចរណ៍ខ្ពស់ ដូចជា **ការស្ថាបនាបណ្តាញផ្លូវនៅខេត្តព្រះសីហនុ និង ខេត្តសៀមរាប**, ព្រមទាំងការអនុម័តនូវឯកសារយុទ្ធសាស្ត្រ និង គោលនយោបាយសំខាន់ៗមួយចំនួនទៀត ដូចជា **វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុង ឆ្នាំ ២០២១-២០២៣**, **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ ២០២១-២០៣៥**, និង **ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តមណ្ឌលគិរី ២០២១-២០៣៥** ជាដើម ។

បទពិសោធន៍ក្នុងរយៈពេលជាង ២ ឆ្នាំចុងក្រោយនេះ បានបង្ហាញថា ការលើកកម្ពស់ចីរភាព និង ការពង្រឹងចលនាទេសចរណ៍ផ្ទៃក្នុង គឺជាគន្លឹះយ៉ាងសំខាន់ក្នុងការពង្រឹងភាពធន់នៃវិស័យទេសចរណ៍ ។ ហេតុនេះ, រាជរដ្ឋាភិបាលបានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវ **គោលនយោបាយជាតិអេកូទេសចរណ៍ ២០១៩-២០៣០** និង បានកំណត់ការអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូ

ទេសចរណ៍ជាស្នូលដ៏សំខាន់ ក្នុងការធ្វើពិពិធកម្មវិស័យទេសចរណ៍ ដើម្បីពង្រឹងមូលដ្ឋាននៃវិស័យទេសចរណ៍, និងជាពិសេស, ធានានូវផលប្រយោជន៍ផ្ទាល់ជូនដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន និង កាត់បន្ថយផលប៉ះពាល់លើធនធានធម្មជាតិ ។ ដើម្បីគាំទ្រដល់សហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍, រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលជាច្រើន ក្រោយពី **វេទិកាជាតិអេកូទេសចរណ៍លើកទី ២** ក្នុងនោះរួមមាន៖ ការបង្កើត **បណ្តាញអេកូទេសចរណ៍បឹងទន្លេសាប**, ការបន្តអនុវត្ត **គម្រោងនិរន្តរភាពតំបន់ទេសភាព និង ទេសចរណ៍ធម្មជាតិកម្ពុជា**, ការដាក់ចេញនូវ **គោល-ការណ៍ណែនាំស្តីពីការបង្កើតសហគមន៍អេកូទេសចរណ៍តាមដងទន្លេមេគង្គលើ** ជាដើម ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ទោះបីជាស្ថានភាពសេដ្ឋកិច្ចសកលនៅមានភាពផុយស្រួយនៅឡើយ, ការអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ នឹងបង្កើតនូវកាលានុវត្តភាពថ្មីៗសម្រាប់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ដែលនឹងមានសិទ្ធិអំណាចផ្ទាល់ក្នុងការរៀបចំ និង ចាត់ចែងអភិវឌ្ឍសហគមន៍របស់ខ្លួន, និងជាពិសេស, មានឱកាសស្វែងរកចំណូលបន្ថែម តាមរយៈវិស័យទេសចរណ៍នៅតាមសហគមន៍របស់ខ្លួន ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

ជាមួយនឹងការអបអរសាទរចំពោះលទ្ធផលនៃ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** នេះ, ខ្ញុំសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹងជាថ្មីម្តងទៀត ចំពោះការបន្តអភិវឌ្ឍសហគមន៍ទេស-ចរណ៍ និង អេកូទេសចរណ៍ ប្រកបដោយចីរភាព និង បរិយាប័ន្ន សម្រាប់វិស័យទេសចរណ៍ទាំងមូល ។ យ៉ាងណាក៏ដោយ, ដើម្បីបន្តពង្រឹង និង ពង្រីកសក្តានុពលនៃការអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍, ខ្ញុំសូមផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួន ដូចខាងក្រោម៖

**ទី១.** ជាមួយនឹងការដាក់ឱ្យអនុម័តនូវ **សេចក្តីថ្លែងការណ៍ស្តីពីការអភិវឌ្ឍសហគមន៍ និង អេកូ-ទេសចរណ៍តាមគន្លងប្រក្រតីភាពថ្មី**, ខ្ញុំសូមស្នើឱ្យអង្គវេទិកាទាំងមូល, ជាពិសេស, ក្រសួងទេសចរណ៍, ក្រសួងបរិស្ថាន និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ព្រមទាំងគណៈអភិបាលរាជធានី-ខេត្ត **បន្តជំរុញការអភិវឌ្ឍសហគមន៍នៅតាមមូលដ្ឋាន ដោយឈរលើស្មារតីនៃកិច្ចសហប្រតិបត្តិការខ្ពស់ ប្រកបដោយភាពជាក់ស្តែងនិយម សំដៅជួយអភិវឌ្ឍសហគមន៍ ទៅតាមជំនាញរៀងៗខ្លួន, ពិសេស សម្រួលដល់ការវិនិយោគនៅតាមសហគមន៍ទេសចរណ៍នានា** ។

**ទី២.** ខ្ញុំសូមអបអរសាទរចំពោះកិច្ចសហការរវាងក្រសួងទេសចរណ៍ និង ក្រសួងបរិស្ថាន ក្នុង **ការកំណត់តំបន់អេកូទេសចរណ៍អាទិភាពថ្នាក់ជាតិ** ដែលនឹងក្លាយជាមូលដ្ឋានដ៏សំខាន់ ក្នុងការជំរុញការអភិវឌ្ឍសកម្មភាពទេសចរណ៍ និង អេកូទេសចរណ៍ក្នុងតំបន់ ។ ក្នុងន័យនេះ, ខ្ញុំសូមស្នើឱ្យ **គ.ជ.អ.អ.** រៀបចំឯកសារគតិយុត្តចាំបាច់នានា ដើម្បីទទួលស្គាល់តំបន់ទាំងនេះជាផ្លូវការឱ្យបានឆាប់, សិក្សាអំពីបរិយាកាសអំណាយផលសម្រាប់ការវិនិយោគ ព្រមទាំងអភិវឌ្ឍ និង ជំរុញការអភិវឌ្ឍដោយឈរលើទស្សនាទាន «**ការអភិវឌ្ឍបម្រើការអភិរក្ស, ការអភិរក្សទ្រទ្រង់ការអភិវឌ្ឍ**» សំដៅធានាការអភិវឌ្ឍប្រកបដោយចីរភាព ។

**ទី៣.** ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាក្នុងសហគមន៍ ដូចជា ការកសាងហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និង ការផ្តល់សេវាសាធារណៈនានា, ខ្ញុំសូមស្នើឱ្យ **គ.ជ.អ.អ. បន្តសិក្សារៀបចំបញ្ជីសហគមន៍អាទិភាព ដើម្បីដាក់បញ្ចូលក្នុងផែនការអាទិភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ** ។ ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលបានសម្រេចសាងសង់បង្គោលអង់តែនទូរស័ព្ទ និង អ៊ីនធើណែត ចំនួន ១០០ បង្គោល នៅតាមតំបន់គោលដៅទេសចរណ៍អាទិភាព និង តំបន់ដាច់ស្រយាល ដែលភាគច្រើនគឺជាតំបន់សហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ ។

**ទី៤.** ខ្ញុំសូមអំពាវនាវឱ្យ**ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និង ហិរញ្ញវត្ថុ ដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តគម្រោងពាក់ព័ន្ធនឹងសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍** ។ ក្នុងស្មារតីនេះ, ខ្ញុំសូមសម្តែងនូវការគាំទ្រចំពោះការ-អនុវត្តគម្រោងពាក់ព័ន្ធនឹងសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ និង សូមស្នើឱ្យ **ឯកឧត្តមបណ្ឌិត ថោង ខុន ប្រធាន គ.ជ.អ.អ.** ចូលរួមសម្របសម្រួល ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការរៀបចំគម្រោង និង ផែនការសកម្មភាពពាក់ព័ន្ធនានា ។

**ទី៥.** ខ្ញុំសូមស្នើឱ្យ **គ.ជ.អ.អ.** សហការជាមួយដៃគូពាក់ព័ន្ធ ជំរុញការផ្សព្វផ្សាយតាមរយៈបច្ចេក-វិទ្យាឌីជីថល ដូចជា៖ ការបង្កើតកម្មវិធីទូរស័ព្ទ (Mobile App) និង ថ្នាលបច្ចេកវិទ្យាឌីជីថល (Digital Platform) ជាដើម សំដៅលើកកម្ពស់ការអនុវត្តយុទ្ធនាការ **ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី** និង **ទេសចរណ៍ផ្សារភ្ជាប់ទឹកដី** ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ។

**ទី៦.** ខ្ញុំគាំទ្រឱ្យមានការរៀបចំ **ពិធីបុណ្យអេកូទេសចរណ៍ប្រចាំឆ្នាំនៅតាមតំបន់អេកូទេសចរណ៍អាទិភាព** ។ ក្នុងន័យនេះ, ខ្ញុំសូមស្នើឱ្យ **គ.ជ.អ.អ.** រៀបចំសំណើគោរពជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់ ។ និង

**ទី៧.** ខ្ញុំសូមស្នើឱ្យ **គ.ជ.អ.អ.** រៀបចំរបាយការណ៍គោរពជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** អំពីលទ្ធផលនៃ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** នេះ ដោយគោរពស្នើសុំការសម្រេចលើដំណោះស្រាយសម្រាប់បញ្ហាប្រឈមនានា ដែលសហគមន៍បាន និង កំពុងជួបប្រទះ ។ បន្ថែមលើនេះ, ខ្ញុំក៏សូមស្នើឱ្យ **គ.ជ.អ.អ.** បន្តជំរុញការអនុវត្តការងារដែលនៅសេសសល់ស្របតាមស្មារតីនៃ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** និង សេចក្តីថ្លែងការណ៍នេះ ហើយផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅដល់គ្រប់ភាគីពាក់ព័ន្ធ ។

- ***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!***

មុននឹងបញ្ចប់, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការរៀបចំ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** នេះឡើង ។ វេទិកានេះបានផ្តល់នូវធាតុចូលដ៏សំខាន់សម្រាប់ការបន្តអភិវឌ្ឍសហគមន៍ទេសចរណ៍ និង អេកូទេសចរណ៍ ដែលនឹងចូលរួមជួយឱ្យកម្ពុជាក្លាយទៅជាគោលដៅទេសចរណ៍លំដាប់ពិភពលោក ។ ខ្ញុំសូមលើកទឹកចិត្តឱ្យមានការរៀបចំ **វេទិកាជាតិអេកូទេសចរណ៍** ជាបន្តបន្ទាប់ និង ជារៀងរាល់ឆ្នាំ ។

នៅទីបញ្ចប់, ខ្ញុំសូមជូនពរឯកឧត្តម, លោកជំទាវ, លោក, លោកស្រី និង អង្គពិធីទាំងមូល បានប្រកបនឹងសុខភាពល្អបរិបូរណ៍, សុភមង្គល និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។

ខ្ញុំសូមប្រកាសបិទ **វេទិកាជាតិអេកូទេសចរណ៍លើកទី ៣** ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***